ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ..០៧៤៨/២៤..អគរ

ថ្ងៃ សុក្រ ១៤ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

## សេចក្តីជូនដំណឹង

### ស្តីពីការផ្អាកជាបណ្តោះអាសន្នលើការនាំចូលគ្រឿងក្នុងនិងបំណែកសាច់បង្កក

យោងតាមសេចក្តីប្រកាសជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមរំលឹក លោក លោកស្រី ជាធុរជនពាក់ព័ន្ធជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចផ្អាកជាបណ្តោះអាសន្នសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ នូវការនាំចូលមុខទំនិញគ្រឿងក្នុង និងបំណែកសាច់បង្កក ដូចខាងក្រោម÷

| ល.រ | លេខកូដទំនិញ | បរិយាយទំនិញ |
|---|---|---|
| ១. | 0206.21.00 | អណ្តាត នៃសត្វគោក្របី បង្កក |
| ២. | 0206.22.00 | ថ្លើម នៃសត្វគោក្របី បង្កក |
| ៣. | 0206.29.00 | គ្រឿងក្នុង (Offal) បង្កក ផ្សេងទៀតនៃសត្វគោក្របី ដែលអាចបរិភោគបាន **ក្រៅពី** អណ្តាត និងថ្លើម |
| ៤. | 0206.41.00 | ថ្លើមនៃសត្វជ្រូក បង្កក |
| ៥. | 0206.49.00 | ភាគបំណែកសាច់និងគ្រឿងក្នុង (Offal) ផ្សេងទៀត **ក្រៅពី** ថ្លើម នៃសត្វជ្រូក ដែលអាចបរិភោគបាន បង្កក |
| ៦. | 0207.14.30 | ថ្លើមនៃសត្វមាន់ បង្កក |
| ៧. | 0207.14.99 | សាច់និងគ្រឿងក្នុង (Offal) បង្កក ផ្សេងទៀតនៃសត្វមាន់ ដែលអាចបរិភោគបាន **ក្រៅពី** ស្លាបទាំងមូល ភ្លៅ ថ្លើម និងសាច់ដែលត្រូវបានយកឆ្អឹងចេញ (Mechanically Deboned or Separated Meat) |
| ៨. | 0504.00.00 | ពោះវៀន ប្លោក និងក្រពះ ទាំងមូល ឬជាផ្នែក នៃសត្វ (លើកលែងត្រី) ស្រស់ ក្លាសេ បង្កក ប្រឡាក់អំបិល ត្រាំទឹកអំបិល សម្ងួត ឬឆ្អើររួច |

ការផ្អាកជាបណ្តោះអាសន្ននូវការនាំចូលខាងលើ ត្រូវបានលើកលែងចំពោះការនាំចូលរបស់គម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ជាធាតុចូលផលិតកម្មសម្រាប់ការនាំចេញ។

អាស្រ័យហេតុនេះ សូមលោក លោកស្រី ជាធុរជនពាក់ព័ន្ធ ជ្រាប និងចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ⅃

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា